សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# អំពើអាណាចារលើ
# អនីតិជន

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សិត ញូន**

សាស្ត្រាចារ្យណែនាំ

លោក **អ៊ឹង រដ្ឋា**

ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី៩

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១១

**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

កិច្ចការសិក្សាស្រាវជ្រាវនេះ ពិពណ៌នាអំពីទិដ្ឋភាពទូទៅនៃអំពើអាណាចារលើអនីតិជន។ ព័ត៌មានដែលលាតត្រដាងក្នុងកិច្ចការស្រាវនេះ ត្រូវបានដកស្រង់ចេញពីច្បាប់ និងលិខិតបទដ្ឋានដែលនៅជាធរមាន។ ចំពោះព័ត៌មានបន្ថែម ដែលមិនមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានខាងលើ គឺត្រូវបានដកស្រង់ចេញពីសិក្ខាសាលា អង្គប្រជុំនានា នឹងជាគំនិតនិងបទពិសោធន៍របស់ខ្ញុំផ្ទាល់។

ខ្ញុំសង្ឃឹមថានិស្សិត មន្ត្រីមានសមត្ថកិច្ចនិងអ្នកដ៏ទៃទៀតដែលបានយកចិត្តទុកដាក់ស្វែងយល់ពីអំពើអានាចារលើអនីតិជននឹងឃើញថាកិច្ចការស្រាវជ្រាវនេះមានប្រយោជន៍។

ទោះបីជាស្នាដៃនេះ បានចូលរួមក្នុងការស្រាវជ្រាវអំពីវិស័យនៃ អំពើអាណាចារលើអនីតិជនក៏ដោយ ក៏ស្នាដៃនេះនៅមិនទាន់ឥតខ្ចោះនៅឡើយ ដោយសារកំហុសឆ្គង។ម្យ៉ាងវិញទៀត ខ្វះចន្លោះនូវពាក្យពេចន៍ឃ្លាប្រយោគក្នុងការតាក់តែងកិច្ចការស្រាវជ្រាវនេះ គឺមិនជៀសផុតឡើយ។ ខ្ញុំរងចាំទទួលនូវមតិរិះគន់បែបស្ថាបនា ពីសំណាក់មិត្តអ្នកអានទាំងអស់ដោយសេចក្តីរីករាយ។

# មាតិកា

**សេចក្តីផ្តើម** ........ 4

**១.អំពីបទល្មើស** ........ 5

១.១ ការស្វែងយល់អំពីអំពើអាណាចារលើអនីតិជន ........ 5

១.២ និយមន័យ "អនីតិជន" ........ 5

១.៣ ការកំណត់អាយុអនីតិជនរងគ្រោះ ........ 5

១.៤ ស្វែងយល់ការកេងប្រវ័ញ្ចផ្លូវភេទលើអនីតិជន ........ 6

១.៥ រូបភាពអាសអាភាសរបស់អនីតិជន ........ 6

១.៥.១ ដើម្បីការសម្រើប និងការស្កប់ស្កល់ក្នុចិត្ត ........ 8

១.៥.២ ការធ្វើឲខូចសុពលភាព យុត្តិកម្មនូវឥរិយាបទអ្នកប្រព្រឹត្តិអំពើអាណាចារលើអនីតិជន ........ 8

១.៥.៣ ដើម្បីកាត់បន្ថយភាពញញើតញញើមរបស់អនីតិជន ........ 9

១.៥.៤ ការរក្សាទុកនូវយុវភាពរបស់អនីតិជន ........ 9

១.៥.៥ វត្ថុតាងទុកសម្រាប់ហែកកេរ្តិ៍ ........ 9

**២.ការជួញដូរអនីតិជនសម្រាប់កាមគុណ** ........ 9

**៣.ការស៊ើបអង្កេត** ........ 9

៣.១ បណ្តាឧបសគ្គដែលបានជួបប្រទះពេលស៊ើបអង្កេត ........ 10

៣.២ អំណាចនៃទឹកប្រាក់ និង/ឬតួនាទី ........ 10

៣.៣ បទបញ្ហាចំពោះនគរបាលយុត្តិធម៌ ........ 10

**៤.ផលវិបាកនៃអំពើអាណាចារលើអនីតិជន** ........ 11

៤.១ ការឈឺសង្កៀរ ........ 11

៤.២ ការអាម៉ាស់មុខ ........ 11

៤.៣ ការដាក់កំហុសលើខ្លួនឯង ........ 11

៤.៤ ការនិរាសព្រាត់ប្រាស់ពីក្រុមគ្រួសារ ........ 11

**សេចក្តីសន្និដ្ឋាន** ........ 12

# សេចក្តីផ្តើម

បទល្មើសឧក្រិដ្ឋដែលពាក់ព័ន្ធនឹងអំពើអាណាចារលើអនីតិជន គឺជាបញ្ហាដ៏ធំមួយក្នុងប្រទេសជាច្រើន នៅទូទាំងសកលលោក។ បញ្ហានេះរីកដុះដាលក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានស្រទាប់ប្រជាជនក្រីក្រ និងអវិជ្ជា។ សព្វថ្ងៃយើងឃើញថា អំពើអាណាចារលើអនីតិជនមានការរីកចំរើនដុះដាលយ៉ាងខ្លាំង។

កម្ពុជាត្រូវបានទទួលរងនូវគ្រោះដោយសារឧប្បត្តិហេតុដ៏អាក្រក់នេះ។ ទន្ទឹមនឹងនេះរដ្ឋាភិបាលយើងបានអនុម័តច្បាប់ពិសេស គឺច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស បានអនុម័តនៅថ្ងៃទី២៩ ខែកុម្ភៈឆ្នាំ១៩៩៦ ដើម្បីផ្តល់អំណាចដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ទប់ទល់ និងចាត់វិធានការ។ រដ្ឋាភិបាលក៏បានចេញសារាចរ និងសេចក្តីថ្លែងការណ៍ជាការណែនាំខាងនីតិកម្មផង ជាយុទ្ធសាស្ត្រជាតិផងស្តីពីវិធានការនានាដែលត្រូវចាត់ឲមានឡើង ដើម្បីអនុវត្តន៍នូវផែនការ៥ឆ្នាំ ប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនដែលត្រូវបាន អនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីខែមេសា ឆ្នាំ២០០០។

មានបុរសខ្មែរមួយចំនួនតូច បានប្រព្រឹត្តអំពើអាណាចារលើអនីតិជន ហើយប្រទេសមួយចំនួន ក៏បានប្រកាសឲប្រើច្បាប់ដែលកំណត់ថា ជាបទល្មើសសម្រាប់ពលរដ្ឋរបស់គេបើជនណាប្រព្រឹត្តអំពើអាណាចារលើអនីតិជន ទោះបីធ្វើដំណើរទេសចរណ៍ឆ្លងកាត់ ឬស្នាក់នៅក៏ដោយ ត្រូវទទួលទោសតាមច្បាប់ប្រទេសរៀងៗខ្លួន។

ដោយយោងទៅលើតម្រូវការច្បាប់ និងសេចក្តីត្រូវការ ឃើញថា បញ្ហានៃអំពើអាណាចារលើអនីតិជនពិបាកនឹងធ្វើការលុបបំបាត់ណាស់ ប្រសិនបើច្បាប់ចែងមិនច្បាស់គ្មានយន្តការត្រឹមត្រូវ និងការអនុវត្តន៍គ្មានប្រសិទ្ធភាពនោះ។ បញ្ហាដែលកើតមានចំពោះមុខនោះ មិនមែនមានតែអំពើអាណាចារលើអនីតិជនតែក្នុងស្រុកទេ បើតាមព័ត៌មាន គឺមានការនាំអនីតិជនទៅក្រៅប្រទេស ក្នុងគោលបំណងធ្វើពេស្យាចារ ឬ ទាសករ ឬកាមគុណទៀតផង។

## ១.អំពីបទល្មើស

ចាត់ទុកជាបទល្មើស កាលណាជនណាមួយបានប្រព្រឹត្តអំពើអាណាចារលើអនីតិជនដែលមានអាយុតិចជាង១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក៏ដោយ។

### ១.១ ការស្វែងយល់អំពីអំពើអាណាចារលើអនីតិជន

ច្បាប់ស្តីពីការអំពើពង្រត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស បានចែងបណ្តាបទល្មើសពិសេសពាក់ព័ន្ធនឹងអំពើអាណាចារលើអនីតិជន។

### ១.២ និយមន័យ " អនីតិជន "

នៅក្នុងច្បាប់រដ្ឋប្បវេណីខ្មែរ បានឲនិយមន័យពាក្យថា " អនីតិជន " គឺជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ។

### ១.៣ ការកំណត់អាយុអនីតិជនរងគ្រោះ

សម្រាប់បទល្មើសមួយចំនួន តុលាការមានការចាំបាច់ជាទីបំផុត ក្នុងការបញ្ជាក់អយុ របស់ជនរងគ្រោះ។ ការបញ្ជាក់អាយុរបស់ជនរងគ្រោះម្នាក់ គឺជាបុព្វកត្តាមួយងាយស្រួលដល់ការចោទប្រកាន់ ឬការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋជនដែលបានប្រព្រឹត្ត។ ដើម្បីបញ្ជាក់ឲដឹងថាជនរងគ្រោះនោះមានអាយុពិតប៉ុន្មាននគរបាលត្រូវមើលសៀវភៅគ្រួសារ ឬសំបុត្រកំណើត ឬក៏សេចក្តីថ្លែងបញ្ជាក់ពីឪពុកម្តាយ ឬជីដូនជីតា ឬមេភូមិ។ មានករណីខ្លះមានតែវេជ្ជបណ្ឌិតជំនាញក្នុងរឿងនេះទេ ដែលអាចបញ្ជាក់ប្រាប់អាយុពិតរបស់អនីតិជនដោយវិធីពិនិត្យវាស់វែងតាមក្បួនពេទ្យ។

**១.៤ ស្វែងយល់ការកេងប្រវ័ញ្ចផ្លូវភេទលើអនីតិជន**

ពាណិជ្ជកម្មកេងប្រវ័ញ្ចផ្លូវភេទលើអនីតិជន គឺជាការប្រើអនីតិជនម្នាក់សម្រាប់គោលបំណងកាមគុណក្នុងការប្តូរយកប្រាក់ ឬរាល់គុណប្រយោជន៍ៗរវាងអតិថិជន អន្តរការី និងអ្នកផ្សេងៗទៀតដែលបានកម្រៃពីការជួញដូរអនីតិជន។

**១.៥ រូបភាពអាសអាភាសរបស់អនីតិជន**

ថ្វីបើនិយមន័យនៃពាក្យនេះមានច្រើនប្លែកៗគ្នាក៏ដោយ អង្គការអន្តរជាតិមួយចំនួនបានមូលមតិគ្នាចបណ្តានិយមន័យទូទៅនៃរូបភាពអាសអាភាសរបស់អនីតិជន ដែលភាគច្រើនផ្តោតទៅលើរូបភាពជាក់ស្តែង ជាជាងអត្ថបទសរសេររ៉ាយរាប់។

ក្រុមប្រឹក្សាទីបអឺរ៉ុបបាននិយមន័យថា "រូបភាពអាសអាភាសរបស់អនីតិជន " ដូចតទៅនេះ៖ សម្ភារៈសោតទស្សន៍(អាចមើលឃើញ និងស្តាប់ឮ)ណាមួយដែលគេប្រើប្រាស់អនីតិជនក្នុងបរិបទ(ស្ថានភាព)កាមគុណណាមួយ។

ចំណែកខាងប្រតិភូអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ(អាំងទែប៉ូល)បានឲនិយមន័យ "រូបភាពអាសអាភាសរបស់អនីតិជន"ថា ការបង្ហាញរូបភាពអំពីសកម្មភាពកេងប្រវ័ញ្ចផ្លូវភេទរបស់អនីតិជនម្នាក់ ដោយប្រមូលផ្តុំលើកាយវិកា សេពសន្ថវៈ ឬអង្គជាតិរបស់អនីតិជន។

និយមន័យដែលគេនិយមចូលចិត្តបំផុត ហើយដែលការពិពណ៌នា " រូបភាពអាសអាភាសអនីតិជន " ដែលយកជាការបានគឺ ការកត់ត្រាទុកជាអចិន្ត្រៃយ៍នូវអំពើរំលោភផ្លូវភេទលើអនីតិជនម្នាក់។

រូបភាពអាសអាភាសរបស់អនីតិជន គឺបាតុភូតអន្តរជាតិមួយ។ នៅក្នុងប្រទេសទាំងឡាយកំពុងអភិវឌ្ឍន៍ សភាពពិតនៃរូបភាពអាសអាភាសរបស់អនីតិជននេះត្រូវបានគេគិតថា ជាបញ្ហាតូចតាចណាស់ បើប្រៀបធៀបទៅនឹងវិសាលភាពនៃបញ្ហាដ៏ទៃទៀត ដូចជា៖ ភាពក្រីក្រ អាត្រាមរណៈនៃទារក អនក្ខភាព ការអត់ឃ្លាន និង ជំងឺ ហើយជាញឹកញាប់គេ

មានទិន្នន័យដែលគួរឲជឿពីរឿងមានចំនួនតិចណាស់។ ទោះបីយ៉ាងណាក៏ដោយ ក៏រូបភាពអាសអាភាសជញ្ជក់យកផលពីអនីតិជន គឺជាបាតុភូតអន្តរជាតិដែលកំពុងកើតមានពាសពេញពិភពលោក។

អនីតិជនគ្រប់រូប រួមទាំងទារកផង ត្រូវបានគេឆ្លៀតយកមកប្រើជាឧទាហរណ៍ ដើម្បីផលិតរូបភាពអាសអាភាសនៅជុំវិញពិភពលោក។ តាមការប៉ាន់ប្រមាណអនីតិជនដែលត្រូវបានគេប្រើ ដើម្បីផលិតរូបភាពអាសអាភាសនេះមានច្រើនសែននាក់។ ក្នុងខណៈយើងមិនអាចស្វែងរក តួលេខឲ្យបានច្បាស់ក៏ពិតមែន តែបើសង្កេតមើលរូបភាពអាសអាភាស របស់អនីតិជនដែលមានស្រាប់ នៅលើទីផ្សារអន្តរជាតិនោះ គេឃើញច្បាស់ក្រឡែតថា មានអនីតិជនយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលកំពុងត្រូវបានគេធ្វើអាជីវកម្មយកផលពីផ្លូវភេទ តាមមធ្យោបាយខាងលើនេះ។

ជនធ្វើអាជីវកម្ម និងផលិតរូបភាពអាសអាភាស គឺជាក្រុមបុគ្គលមួយជំពូក រស់នៅក្នុងសហគមន៍ដែលរួមមានសមាជិកដ៏គួរឲគោរពរាប់អានពីសំណាក់ប្រជារាស្ត្រផង ដែរ។ ម្យ៉ាងទៀត ជនជំពូកនោះតែងតែស្វែងរកមុខរបរដែលមានទំនាក់ទំនងជាប្រក្រតីជាមួយអនីតិជន។ ផលិតករ(រួមបញ្ចូលទាំងអ្នកថតរូប អ្នកបោះពុម្ពផ្សាយ និងអ្នកផលិតភាពយន្តវីដេអូនៅតាមគេហដ្ឋាន) អន្តរការី(រាប់បញ្ចូលទាំងសញ្ជារិក សញ្ជារិកា និងឪពុកម្តាយ) អ្នកចែកផ្សាយ(រួមទាំងអ្នកផ្សព្វផ្សាយ និងអ្នកលក់ដូរ) ក៏ដូចជាអ្នកប្រមូលផ្តុំទិញស្តុកទុកនូវរូបភាពអាសអាភាសរបស់អនីតិជន ត្រូវបានរាប់បញ្ចូលក្នុងប្រភេទអ្នកធ្វើអាជីវកម្មផ្លូវភេទលើអនីតិជន។

អ្នកចូលចិត្តប្រព្រឹត្តអំពើផ្លូវភេទលើអនីតិជន(និងពិពណ៌នាក្នុងសៀវភៅនេះ) បង្កបង្កើនផ្នែកសំខាន់ៗមួយនៃបណ្តាបទល្មើស។ រូបភាពអាសអាភាសអនីតិជនបម្រើគោលបំណងសំខាន់របស់អ្នកចូលចិត្តប្រព្រឹត្តអំពើផ្លូវភេទលើអនីតិជនដែលតែងតែប្រមែប្រមូលស្តុកទុករូបភាពអាសអាភាសអនីតិជនយ៉ាងទូលំទូលាយដោយបានរៀបចំជាកាតាឡុកដ៏ល្អហើយថែរក្សាទុកដោយប្រុងប្រយ័ត្ន។ ពិសេសទៅទៀត មិនមានតែពួកគេទេដែលជាអ្នកផលិត និងប្រើប្រាស់រូបភាពអាសអាភាសអនីតិជន។ មានបុគ្គលច្រើនទៀតក្នុងស្រទាប់ប្រជាជនទូទៅ ដែលមានការចាប់អារម្មណ៍លើរូបភាពអាសអាភាសរបស់អនីតិជន ដែល

បានបង្ហាញពីយោពនភាព(ភាពកំពុងពេញរូបរាងជាក្រមុំ កម្លោះ)។ បន្ថែមពីលើនោះ ដោយមានភាពផុសផុលការប្រើប្រាស់កុំព្យូទ័រ ដើម្បីបញ្ចូលរូបភាពអាសអាភាសរបស់អនីតិជននោះ គេបានសង្កេតឃើញអ្នកផលិត និងអ្នកប្រើប្រាស់កាន់តែកើនឡើងៗទៀតដែរ។ ជនជំពូកនេះ ប្រហែលជាមិនមែនជាអ្នកប៉ងប្រាថ្នា ដើម្បីសេពសន្ថវៈជាមួយ អនីតិជននោះទេ តែដោយសារពួកគេធ្លាប់ឃើញ ធ្លាប់មើលរូបភាពអាសអាភាសមនុស្សជាច្រើនមកហើយ ហើយពេលនោះប្រហែលចង់ស្វែងរកបណ្តាប្រភេទផ្សេងៗទៀត នៃ សម្ភារៈអាសអាភាស។

ប្រភពមួយទៀតខាងការចែកចាយរូបភាពអាសអាភាសរបស់អនីតិជនទូទាំងពិភពលោក នោះគឺត្រូវបានបង្កើតឡើងដោយទេសចរញៀនកាមគុណ ដែលធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗ ដើម្បីរកសេពសន្ថវៈតែជាមួយនឹងអនីតិជន។

បណ្តាអ្នកជំនាញការបានរៀបរាប់មូលហេតុមួយចំនួនថា ហេតុអ្វីបានជាមានអ្នកប្រមែប្រមូលរក្សាទុកនូវរូបភាពអាសអាភាសអនីតិជនដូចតទៅៈ

**១.៥.១ ដើម្បីការសម្រើប និងការស្កប់ស្កល់ក្នុងចិត្ត**

ជនជំពូកខ្លះប្រើរូបភាពអាសអាភាស ដើម្បីធ្វើឲរូបគេត្រេកត្រអាល ហើយបង្កើននូវចំណងសេពសន្ថវៈ ចំណែកអ្នកផ្សេងទៀតអាចប្រើប្រាស់សម្រាប់ធ្វើជាគំរូ មុនពេលចាប់ផ្តើមធ្វើសកម្មភាពសេពសន្ថវៈមែនទែនជាមួយអនីតិជន។

**១.៥.២ ការធ្វើឲខូចសុពលភាព យុត្តិកម្មនូវឥរិយាបទអ្នកប្រព្រឹត្តិអំពើអាណាចារលើអនីតិជន**

ជនចូលចិត្តប្រព្រឹត្តិអំពើអាណាចារលើអនីតិជន ដោយប្រើរូបភាពអាសអាភាសដើម្បីធ្វើឲខ្លួនគេជឿជាក់ជាឥរិយា ឬទង្វើនាំឲនឹកឃើញជានិច្ចរបស់ពួកគេនោះ មិនមែនរឿងអាស្រូវខុសធម្មតាទេ។

**១.៥.៣ ដើម្បីកាត់បន្ថយភាពញញើតញញើមរបស់អនីតិជន**

ជនអ្នករំលោភអនីតិជន ប្រើរូបភាពរបស់អនីតិជនផ្សេងទៀតដែលកំពុងសេពសន្ថវៈ ដើម្បីជាជំនួយក្នុងការប្រលោមអនីតិជន ហើយធ្វើដូច្នេះដើម្បីកម្លាចិត្តអនីតិជនណាដែលមានការស្ទាក់ស្ទើរនៅឡើយ ឲសុកចិត្តសេពសន្ថវៈជាមួយគេដោយមិនចាំបាច់បង្ខំ។

**១.៥.៤ ការរក្សាទុកនូវយុវភាពរបស់អនីតិជន**

រូបភាពអាសអាភាសរបស់អនីតិជន ធានាថាជានិច្ចកាលនឹងមានរូបភាពមួយរបស់អនីតិជនដែលស្ថិតនៅក្នុងវ័យមានចំណង់ចំណូលចិត្តសេពសន្ថវៈ។

**១.៥.៥ វត្ថុតាងទុកសម្រាប់ហែកកេរ្តិ៍**

ជានិច្ចកាល អនីតិជនរងគ្រោះនឹងមិនហ៊ានរាយការណ៍ប្រាប់ពីរឿងរូបភាពនោះទេ ថ្វីបើពួកគេបានរាយរ៉ាប់ពីអំពើអាណាចារខាងផ្លូវភេទក៏ដោយ ព្រោះថា ពួកគេអាចមានការអៀនខ្មាសអំពីអ្វីដែលបានកើតឡើងចំពោះពួកគេ។

## ២.ការជួញដូរអនីតិជនសម្រាប់កាមគុណ

និយមន័យ: រាល់អំពើប្រព្រឹត្ត ឬប៉ុនប៉ងទាក់ទងនឹងការជ្រើសរើស ដឹកជញ្ជូននៅក្នុងប្រទេស ឬឆ្លងកាត់ព្រំដែន ទិញ លក់ ផ្ទេរ ឃុំគ្រងទុក ឬទទួលយកមនុស្សម្នាក់ពាក់ព័ន្ធនឹងការប្រើវិធីបោកបញ្ឆោត និងការបង្ខិតបង្ខំដោយការគម្រាមប្រើកម្លាំងបាយ ឬការអាណាចារដោយអំណាច ឬបំណុលជាចំណងសម្រាប់គោលដៅឃាត់ឃាំងមនុស្សនេះទុក ដើម្បីធ្វើការឲប្រាក់ ឬមិនឲប្រាក់ក្តី ឲស្ថិតនៅក្នុងសេរភាពអចេតនា(ជាអ្នកបម្រើកិច្ចការផ្ទះ កាមគុណ សម្រាប់បន្តពូជ) ក្នុងស្ថានភាពត្រូវបង្ខិតបង្ខំ ឬមានចំណង ឬដូចទាសករក្នុងសហគមន៍មួយទៀតក្រៅពីទីកន្លែងដែលជននោះធ្លាប់រស់នៅមុនពេលត្រូវគេបោកបញ្ឆោត បង្ខំចិត្តដោយយកបំណុលជាចំណង។

## ៣.ការស៊ើបអង្កេត

ដូចបានពណ៌នាខាងលើ មានបញ្ហាស្មុគស្មាញជាច្រើន អាចជះឥទ្ធិពលដល់ការស៊ើបអង្កេត បណ្តាករណីទាក់ទងនឹងអំពើអាណាចារលើអនីតិជន។ បញ្ហាទាំងនេះ រួមមានជំនាញឯកទេសធ្វើការសំភាសន៍អនីតិជន ចរិតលក្ខណៈរបស់ជនល្មើស និងភាពស្មុក

ស្នាញរបស់ច្បាប់។ បញ្ហាទាំងនេះ ទាមទារឲអ្នកស៊ើបអង្កេត ត្រូវតែមានការយល់ដឹងសុក្រឹតមួយ អំពីការវិនិច្ឆ័យយ៉ាងច្បាស់លាស់នូវអ្វីដែលទាក់ទងនឹងការស៊ើបអង្កេត ករណីរបៀបនេះ។

### ៣.១ បណ្ដាឧបសគ្គដែលបានជួបប្រទះពេលស៊ើបអង្កេត

ការស៊ើបអង្កេតបណ្ដាបទល្មើសដែលទាក់ទងនឹងអំពើអាណាចារលើអនីតិជនអាចត្រូវរងឥទ្ធិពលពីបណ្ដាកត្តាខាងក្នុង និងខាងក្រៅមួយចំនួន ជាការសំខាន់សម្រាប់ការស៊ើបអង្កេតដែលត្រូវយល់ដឹងពីបណ្ដាឧបសគ្គដែលអាចជួបប្រទះនៅពេលដំណើរការស៊ើបអង្កេតករណីប្រភេទនេះ។

### ៣.២ អំណាចនៃទឹកប្រាក់ និង/ឬតួនាទី

បណ្ដាទិដ្ឋភាពជាច្រើននៃការកេងប្រវ័ញ្ចផ្លូវភេទលើអនីតិជន ពាក់ព័ន្ធនឹងសមាសភាពពាណិជ្ជកម្មមួយ។ សមាសភាពនេះ អាចមានឥទ្ធិលពលធ្ងន់ធ្ងរមួយលើការស៊ើបអង្កេត បណ្ដាបទ ល្មើសទាក់ទងនឹងអំពើអាណាចារលើអនីតិជន។ ទឹកប្រាក់ត្រូវបានគេយកទៅទិញទឹកចិត្តជនរងគ្រោះឲនៅស្ងៀម ឬសូកអ្នកស៊ើបអង្កេត និង/ឬមន្ត្រីតុលាការ។

### ៣.៣ បទបញ្ជាចំពោះនគរបាលយុត្តិធម៌

មន្ត្រីនគរបាលដែលត្រូវបានអនុញ្ញាតឲធ្វើជានគរបាលយុត្តិធម៌(នគរបាលតុលាការ) គប្បីយល់ដឹងពីការអនុវត្តន៍មាត្រា៩៨នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋកម្ពុជា។

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌គ្មានសិទ្ធតម្កល់រឿងទុកឥតចាត់ការដែលខ្លួនបានទទួល ទោះមានការសម្របសម្រួលព្រមព្រៀងគ្នាក៏ដោយ ក៏ត្រូវធ្វើកំណាត់ហេតុបញ្ជូនទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចជាដ៏រាប។ ជាពិសេស ពេលទទួលបានរបាយការណ៍អំពីបទល្មើសម្ដងៗគេគ្មានសិទ្ធិដោះស្រាយបញ្ហាដោយពុំបានរាយការណ៍ជូនព្រះរាជអាជ្ញានោះទេ។

## ៤.ផលវិបាកនៃអំពើអាណាចារលើអនីតិជន

ដើម្បីឲនគរបាលធ្វើការសម្ភាសន៍អនីតិជន ដែលមានអំពើអាណាចារប្រកបដោយប្រសិទ្ធភាព គេត្រូវមានការយល់ដឹងមួយអំពីផលប៉ះពាល់នានា ស្តីពីអំពើអាណាចារលើអនីតិជនដូចខាងក្រោមៈ

### ៤.១ ការឈឺសង្វៀរ

ការឈឺសង្វៀរ គឺជាការរំលោភលើបណ្តាទិដ្ឋភាពរូមភេទ និងបុគ្គលផ្ទាល់ខ្លួនរបស់មនុស្ស។ រាងកាយនៃមនុស្សម្នាក់ ត្រូវបានមនុស្សម្នាក់ទៀតយកទៅធ្វើជាទីលានសម្រាប់អាណាចារយ៉ាងឃោរឃៅ។

### ៤.២ ការអាម៉ាស់មុខ

ប្រតិកម្មមួយយ៉ាងខ្លាំងខាងផ្លូវចិត្ត តែងជិតជាប់នឹងធម្មជាតិផ្លូវភេទ និងការសង្វៀរ។ តម្លៃបុគ្គលរបស់អនីតិជនត្រូវរលាយអស់រហូតដល់ចំណុចមួយដែលគិតថាគ្មានជម្រើសផ្សេងទៀត ព្រោះថាអ្វីៗទាំងអស់លែងមានតម្លៃ។

### ៤.៣ ការដាក់កំហុសលើខ្លួនឯង

អនីតិជនភាគច្រើនតែងតែដាក់កំហុសលើខ្លួនឯងថា មកពីព្រេងវាសនា និងមានន័យមួយបំផ្លើសអំពីចំណែករបស់ខ្លួនក្នុងផលកម្ម ដែលជម្រុញឲធ្លាក់ក្នុងស្ថានភាពបែបនេះ។

### ៤.៤ ការនិរាសព្រាត់ប្រាស់ពីក្រុមគ្រួសារ

ទំនាក់ទំនងសាច់ញាតិសំខាន់ៗត្រូវបាត់បង់ ហើយអនីតិជនភាគច្រើន កើតទុកដោយសារដាច់ការទាក់ទង ជាពិសេសជាមួយបងប្អូន។

# សេចក្តីសន្និដ្ឋាន

អំពើអាណាចារលើអនីតិជន ជាអំពើមួយដែលអាក្រក់បំផុត និងមិនគួរឲ្យកើតមានចំពោះអនីតិជន។ កាលណាមានអំពើនេះកើតឡើង ជាកត្តានាំឲ្យអនីតិជនជួបនូវផលវិបាកដូចជា៖ បាត់បង់កេរ្តិ៍ឈ្មោះ និរាសព្រាត់ប្រាស់គ្រួសារ ធ្វើឲ្យមានការគិតខ្លី និងបាត់បង់អនាគតជាដើម។

ដូច្នេះ ដើម្បីជៀសវាងកុំឲ្យកើតមានអំពើអាណាចារលើអនីតិជន ត្រូវពង្រឹង និងអនុវត្តន៍ច្បាប់ឲមានប្រសិទ្ធភាពបំផុត៕